# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

CAMBODIA
Kingdom of Wonder
feel the warmth

ក្រសួងទេសចរណ៍

លេខ ០០៣ សប្រក

ថ្ងៃព្រហស្បតិ៍ ៤ រោច ខែ ចេត្រ ឆ្នាំ ជូត ទោ ស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០២១

## សេចក្តីប្រកាសព័ត៌មាន

ក្រសួងទេសចរណ៍ មានកិត្តិយសជម្រាបជូនសាធារណៈជន ប្រតិបត្តិករទេសចរណ៍ ជ្រាបថា កាលពីថ្ងៃអង្គារ ២រោច ខែចេត្រ ឆ្នាំជូត ទោស័ក ពុទ្ធសករាជ ២៥៦៤ ត្រូវនឹងថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២១ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានអនុម័តជាផ្លូវការលើ **"ផែនទីចង្អុលផ្លូវ (Roadmap) ស្តីពី ផែនការស្តារ និងលើកស្ទួយវិស័យទេសចរណ៍កម្ពុជា ក្នុង និងក្រោយវិបត្តិជំងឺកូវីដ-១៩"** និង **"ផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តសៀមរាប ២០២១-២០៣៥"** ដែលមានខ្លឹមសារសំខាន់ៗដូចខាងក្រោម÷

**១. ផែនទីចង្អុលផ្លូវ (Roadmap) ស្តីពី ផែនការស្តារ និងលើកស្ទួយវិស័យទេសចរណ៍កម្ពុជា ក្នុង និងក្រោយវិបត្តិជំងឺកូវីដ-១៩**

វិស័យទេសចរណ៍ ជាវិស័យអាទិភាពក្នុងការរួមចំណែកអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកម្ពុជា។ វិស័យទេសចរណ៍ ក៏ដូចជាវិស័យនានាបានទទួលរងផលប៉ះពាល់យ៉ាងខ្លាំងពីវិបត្តិជំងឺកូវីដ-១៩។ សម្រាប់កម្ពុជា ការស្តារឡើងវិញនៃវិស័យនេះ ទាមទារឱ្យមានការគិតគូរ និងតម្រង់ទិសច្បាស់លាស់ និងគ្រប់ជ្រុងជ្រោយ។ ក្នុងន័យនេះ **"ផែនទីចង្អុលផ្លូវ (Roadmap) ស្តីពី ផែនការស្តារ និងលើកស្ទួយវិស័យទេសចរណ៍កម្ពុជា ក្នុង និងក្រោយវិបត្តិជំងឺកូវីដ-១៩"** នឹងក្លាយជាត្រីវិស័យ និងជាផែនការយុទ្ធសាស្ត្រមួយដ៏សំខាន់ ដើម្បីធានាដាក់ចេញវិធានការអន្តរាគមន៍ទាន់ពេលវេលា។ ផែនទីចង្អុលផ្លូវ នឹងកំណត់នូវចក្ខុវិស័យក្នុងការប្រែក្លាយវិបត្តិជំងឺកូវីដ-១៩ ទៅជាកាលានុវត្តភាពសម្រាប់ការកែទម្រង់ក្នុងវិស័យទេសចរណ៍កម្ពុជាឱ្យទៅជាគោលដៅទេសចរណ៍គុណភាព, សុវត្ថិភាព និងនិរន្តរភាព ដោយទាញយកមកវិញនូវចំនួនភ្ញៀវទេសចរអន្តរជាតិ និងជំរុញសកម្មភាពទេសចរណ៍ក្នុងស្រុក។

ផែនទីចង្អុលផ្លូវ (Roadmap) ស្តីពី ផែនការស្តារ និងលើកស្ទួយវិស័យទេសចរណ៍កម្ពុជា ក្នុង និងក្រោយវិបត្តិជំងឺកូវីដ-១៩ ត្រូវបានរៀបចំឡើងដោយក្រសួងទេសចរណ៍ និងបានទទួលការឯកភាពគាំទ្រពីគណៈកម្មាធិការជាតិអភិវឌ្ឍន៍ទេសចរណ៍ គណៈកម្មការអប់រំ យុវជន កីឡា ធម្មការ កិច្ចការសាសនា វប្បធម៌ និងទេសចរណ៍នៃរដ្ឋសភា ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងវិស័យឯកជន។

ផែនការស្តារ និងលើកស្ទួយវិស័យទេសចរណ៍នេះ នឹងត្រូវអនុវត្តជា ០៣ ដំណាក់កាល រួមមាន÷ **ដំណាក់កាលទី១ (Resilience & Restart)**÷ ការគ្រប់គ្រងវិបត្តិក្នុងដំណាក់កាលទម្លាប់ថ្មី (New Normal) និងរៀបចំផែនការសម្រាប់ការស្តារឡើងវិញ (២០២១), **ដំណាក់កាលទី២ (Recovery)**÷ ការស្តារឡើងវិញនៃវិស័យទេសចរណ៍កម្ពុជាក្រោយវិបត្តិជំងឺកូវីដ-១៩ (២០២២ - ២០២៣), និង **ដំណាក់កាលទី៣ (Relaunch)** ÷ ការរៀបចំឆ្ពោះទៅកាន់អនាគតថ្មីនៃវិស័យទេសចរណ៍កម្ពុជា (២០២៤-២០២៥)។

ឡូតិ៍លេខ៣A ផ្លូវលេខ១១៦៩ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ: +៨៥៥ ២៣ ៨៨៤ ៩៧២ ទូរសារ: +៨៥៥ ២៣ ៨៨៤ ៩៧៤ E-mail: admin@mot.gov.kh Website: www.tourismcambodia.org

ផែនទីចង្អុលផ្លូវនេះមានយុទ្ធសាស្ត្រសរុបចំនួន ០៩, សកម្មភាពយុទ្ធសាស្ត្រចំនួន ៤៩ និងសកម្មភាពយុទ្ធសាស្ត្រលម្អិតចំនួន ១៨០ រួមជាមួយគម្រោងកម្មវិធីអាទិភាពចំនួន ១៧។ បន្ថែមលើនេះ ដើម្បីដឹកនាំ និងតាមដានការអនុវត្តផែនការសកម្មភាពក្នុងដំណាក់កាលនីមួយៗ នៃផែនទីចង្អុលផ្លូវនេះ រាជរដ្ឋាភិបាលនឹងរៀបចំយន្តការអន្តរស្ថាប័នមួយ។

**ការអនុម័តផែនទីចង្អុលផ្លូវ (Roadmap) ស្តីពី ផែនការស្តារ និងលើកស្ទួយវិស័យទេសចរណ៍កម្ពុជាក្នុង និងក្រោយវិបត្តិជំងឺកូវីដ-១៩ នាពេលនេះ គឺស្របពេលដែលរាជរដ្ឋាភិបាលបានកំពុងប្រកាសជំរុញយុទ្ធនាការចាក់វ៉ាក់សាំងជូនប្រជាពលរដ្ឋ និងពង្រឹងយន្តការគ្រប់គ្រងការឆ្លងរីករាលដាលកូវីដ-១៩ក្នុងសហគមន៍ផងដែរ។**

## ២. ផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តសៀមរាប ២០២១-២០៣៥

**ផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តសៀមរាប ២០២១-២០៣៥** ត្រូវបានរៀបចំដោយ **"គណៈកម្មការអន្តរក្រសួងដើម្បីសិក្សារៀបចំផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តសៀមរាប"** ដឹកនាំដោយ**ឯកឧត្តម ថោង ខុន** រដ្ឋមន្ត្រីក្រសួងទេសចរណ៍ និងជាប្រធានគណៈកម្មការអន្តរក្រសួង និងបានទទួលការឯកភាព និងគាំទ្រពីគណៈកម្មាធិការជាតិអភិវឌ្ឍន៍ទេសចរណ៍ដែលមាន **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** ជាប្រធាន។

ផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តសៀមរាប មានគោលដៅធ្វើឱ្យខេត្តសៀមរាបអាចក្តាប់យក**មកវិញនូវមោទនភាពជាគោលដៅទេសចរណ៍ចម្បងក្នុងប្រទេសកម្ពុជា និងក្នុងតំបន់អាស៊ីអាគ្នេយ៍** ក្នុងរយៈពេលមធ្យម និងវែងខាងមុខ។ ផែនការមេនេះ កំណត់ចក្ខុវិស័យឱ្យខេត្តសៀមរាបទាក់ទាញ និងទទួលភ្ញៀវទេសចរជាតិ និងអន្តរជាតិចំនួនប្រមាណ **១៨,៤ លាននាក់** ក្នុងនោះភ្ញៀវទេសចរជាតិចំនួនប្រមាណ **១០,៩លាននាក់** និងទេសចរអន្តរជាតិចំនួនប្រមាណ **៧,៥លាននាក់,** បង្កើតការងារប្រមាណ **៩៤ម៉ឺននាក់,** នាំចំណូលហូរចូលក្នុងចរន្តសេដ្ឋកិច្ចខេត្តសៀមរាបប្រមាណ **៦ ពាន់លានដុល្លារអាមេរិក** និងធ្វើឱ្យខេត្តនេះ និងតំបន់ជុំវិញ ក្លាយជា **"គោលដៅទេសចរណ៍ប្រកបដោយគុណភាព" ឆ្ពោះទៅឆ្នាំ ២០៣៥** តាមរយៈការដាក់ចេញ និងអនុវត្តនូវគោលដៅយុទ្ធសាស្ត្រ **ចំនួន ០៧** រួមមាន÷ (១). ការអភិវឌ្ឍតំបន់ទេសចរណ៍អាទិភាពនៅខេត្តសៀមរាប, (២). ការអភិវឌ្ឍផលិតផលទេសចរណ៍ថ្មីៗ, (៣). ការផ្សព្វផ្សាយ និងទាក់ទាញទេសចរណ៍មកខេត្តសៀមរាប, (៤). ការពង្រឹងគុណភាព និងនិរន្តរភាព នៃការអភិវឌ្ឍទេសចរណ៍ខេត្តសៀមរាប, (៥). ការគ្រប់គ្រងបរិស្ថាននៅខេត្តសៀមរាប, (៦). ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងពង្រឹងការតភ្ជាប់គាំទ្រវិស័យទេសចរណ៍នៅខេត្តសៀមរាប និង (៧). ការពង្រឹងអភិបាលកិច្ចសម្រាប់ទ្រទ្រង់ការអភិវឌ្ឍវិស័យទេសចរណ៍នៅខេត្តសៀមរាប។ ផែនការមេនេះ ដាក់ចេញនូវ **យុទ្ធសាស្ត្រសរុបចំនួន ៤៤ សកម្មភាពអនុវត្តសរុបចំនួន ១៣៦** សម្រាប់រយៈពេលខ្លី រយៈពេលមធ្យម និងរយៈពេលវែង អមជាមួយគម្រោងសកម្មភាពអាទិភាព **ចំនួន ២០។**

ក្រសួងទេសចរណ៍នឹងបន្តពិភាក្សាជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ដើម្បីជំរុញការអនុវត្តឯកសារដ៏មានសារៈសំខាន់ជាយុទ្ធសាស្ត្រទាំង២នេះ ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។